OLD COLONY
PLANNING COUNCIL

Rebecca Coletta, President | Mary Waldron, Executive Director

(508) 583-1833 | 70 School Street, Brockton, MA 02301 | www.oldcolonyplanning.org

# នីតិវិធីដាក់ពាក្យបណ្តឹងតាមមាត្រា 6

## គោលបំណង និងវិសាលភាពអនុវត្ត

ឯកសារនេះមានគោលបំណងដើម្បីបង្កើតនីតិវិធីសម្រាប់ដំណើរការ និងចាត់ចែងទាំងបណ្តឹងស្តីពីរើសអើងដែលបានដាក់ដោយផ្ទាល់ទៅកាន់នាយកដ្ឋានដឹកជញ្ជូនរដ្ឋ Massachusetts (MassDOT) ឬអាជ្ញាធរដឹកជញ្ជូន Massachusetts Bay (MBTA) និងពាក្យបណ្តឹងស្តីពីការរើសអើងដែល MassDOT/MBTA មានសិទ្ធិអំណាចដែលបានប្រគល់ជូន ដើម្បីដំណើរការក្រោមមាត្រា 6 នៃច្បាប់ស្តីពីសិទ្ធិពលរដ្ឋឆ្នាំ 1964 (មាត្រា 6) និងអាជ្ញាធរប្រឆាំងការរើសអើងថ្នាក់រដ្ឋ និងសហព័ន្ធដែលពាក់ព័ន្ធ រួមទាំងច្បាប់ស្តីពីជនពិការអាមេរិក (ADA) ផងដែរ។

ដំណើរការពាក្យបណ្តឹងស្តីពីការរើសអើងនឹងអនុវត្តតាមដំណាក់កាលដូចដែលបានរៀបរាប់ខាងក្រោម ហើយមានរៀបរាប់លម្អិតបន្ថែមនៅក្នុងឯកសារនេះ។

- ដំណាក់កាលទី 1៖ ដើមបណ្តឹងដាក់ពាក្យបណ្តឹង។
- ដំណាក់កាលទី 2៖ MassDOT/MBTA ចេញលិខិតទទួលស្គាល់ជូនដើមបណ្តឹង។
- ដំណាក់កាលទី 3៖ ពាក្យបណ្តឹងត្រូវបានចាត់តាំង និងពិនិត្យដោយអ្នកស៊ើបអង្កេត។
- ដំណាក់កាលទី 4៖ អ្នកស៊ើបអង្កេតដើមបណ្តឹង សាក្សី និងចុងបណ្តឹង។
- ដំណាក់កាលទី 5៖ អ្នកស៊ើបអង្កេតពិនិត្យមើលភស្តុតាង និងសក្ខីកម្ម ដើម្បីកំណត់ថាតើមានការរំលោភបំពាន ដែរឬទេ។
- ដំណាក់កាលទី 6៖ ដើមបណ្តឹង និងចុងបណ្តឹងត្រូវបានចេញលិខិតដោះស្រាយ ឬលិខិតស្វែងរក និងផ្តល់សិទ្ធិប្តឹងឧទ្ធរណ៍។
- ដំណាក់កាលទី 7៖ នៅពេលដែលរយៈពេលនៃការប្តឹងឧទ្ធរណ៍ផុតកំណត់ ការស៊ើបអង្កេតនឹងបិទ។

នីតិវិធីទាំងនេះរៀបរាប់ពីដំណើរការរដ្ឋបាលដែលមានគោលដៅកំណត់សម្គាល់ និងលុបបំបាត់ការរើសអើងនៅក្នុងសកម្មភាព និងកម្មវិធីនានាដែលទទួលជំនួយពីសហព័ន្ធ។ នីតិវិធីទាំងនេះមិនផ្តល់មធ្យោបាយដោះស្រាយដល់ដើមបណ្តឹងដែលស្វែងរកដំណោះស្រាយផ្លូវច្បាប់ ដែលរួមមានសំណងជំងឺចិត្ត ឬប្រាក់ទូទាត់ឡើយ។ នីតិវិធីទាំងនេះក៏មិនហាមឃាត់ដើមបណ្តឹងមិនឱ្យទៅដាក់ពាក្យប្តឹងទៅកាន់នឹងភ្នាក់ងាររដ្ឋ និងសហព័ន្ធផ្សេងទៀត ឬក៏បដិសេធសិទ្ធរបស់ដើមបណ្តឹងក្នុងការស្នើសុំការផ្តល់ប្រឹក្សាជាលក្ខណៈឯកជនសម្រាប់ដោះស្រាយទង្វើរើសអើងដែលបានចោទក្នុងពាក្យបណ្តឹងនោះដែរ។

នីតិវិធីដែលបានរៀបរាប់ក្នុងឯកសារនេះត្រូវបានអនុវត្តចំពោះ MassDOT/MBTA និងអ្នកទទួលជំនួយបន្ត ក្រុមហ៊ុនម៉ៅការ និងក្រុមហ៊ុនម៉ៅការបន្ត នៅក្នុងការការគ្រប់គ្រងសកម្មភាព និងកម្មវិធីនានាដែលទទួលជំនួយពីសហព័ន្ធ។

ជាផ្នែកមួយនៃកិច្ចខំប្រឹងប្រែងនៅក្នុងការអនុវត្តតាមមាត្រា 6
អ្នកទទួលជំនួយហិរញ្ញវត្ថុពីសហព័ន្ធតាមរយៈ MassDOT/MBTA
ត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់នីតិវិធីនៃការដាក់ពាក្យបណ្តឹងនេះ។
ការប្រើប្រាស់នីតិវិធីនេះបញ្ជាក់ថាអ្នកទទួលជំនួយបន្តទាំងនេះ
ទទួលស្គាល់កាតព្វកិច្ចរបស់ពួកគេក្នុងការផ្តល់ឱកាសឱ្យសាធារណជនដាក់ពាក្យបណ្តឹងប្រឆាំង
នឹងការបំពានគោលនយោបាយប្រឆាំងការរើសអើងនៅក្នុងគ្រប់សកម្មភាព សេវាកម្ម
និងកម្មវិធីនានារបស់អង្គភាព។ ដោយគោរពតាមការណែនាំរបស់សហព័ន្ធ
អ្នកទទួលជំនួយបន្តទាក់ទងនឹងការធ្វើដំណើរ
យល់ដឹងថាពួកគេមានសិទ្ធិអំណាចក្នុងការអនុវត្តបណ្តឹងមាត្រា 6
រួចផ្តល់ដំណឹងដល់អ្នកទទួលជំនួយដែលជា MassDOT/MBTA
អំពីពាក្យបណ្តឹងដែលគេបានទទួល និង
លទ្ធផលនៃការស៊ើបអង្កេតនៅពេលដែលដោះស្រាយពាក្យបណ្តឹង។

អ្នកទទួលជំនួយបន្តទាក់ទងនឹងការធ្វើដំណើរលើផ្លូវធំ កាន់តែយល់ថា
ពួកគេគ្មានសិទ្ធិអំណាចក្នុងការស៊ើបអង្កេត ពាក្យបណ្តឹងស្តីពីបទល្មើសមាត្រា 6
ដែលមានអង្គភាពរបស់ពួកគេជាចុងបណ្តឹងនោះទេ (ប្រសិនអង្គភាពរបស់ពួកគេជាចុងបណ្តឹង
ឬ ភាគីដែលត្រូវបានគេចោទថាបានល្មើសមាត្រា 6) ។ គ្រប់ពាក្យបណ្តឹងទាំងនេះ
នឹងត្រូវគេបញ្ជូនទៅ MassDOT/MBTA ដើម្បីធ្វើការសម្រេចថា
អង្គភាពណាមានសិទ្ធស៊ើបអង្កេត។ អ្នកទទួលជំនួយបន្តទាក់ទងនឹងការធ្វើដំណើរលើផ្លូវធំ
រក្សាសិទ្ធពិចារណាថាការចោទប្រកាន់នៃការល្មើសមាត្រា 6 ជាបញ្ហារ៉ាប់រង និង/ឬ
បញ្ហានៃការគោរពគោលការណ៍ផ្ទៃក្នុង
ប៉ុន្តែពួកគេត្រូវបានហាមឃាត់មិនឱ្យចេញសេចក្តីសម្រេច
ព្រោះនេះអាចជាការល្មើសទៅនឹងមាត្រា 6។ MassDOT/MBTA
សូមលើកទឹកចិត្តឱ្យអ្នកទទួលជំនួយបន្តទាំងអស់ទាក់ទងទៅអ្នកជំនាញមាត្រា 6 របស់ ODCR
ដែលជានាយកគ្រប់គ្រងកម្មវិធីសហព័ន្ធ និង/ឬ នាយកគ្រប់គ្រងស៊ើបអង្កេត
នៅពេលដែល/ប្រសិនបើពួកគេបានទទួលពាក្យបណ្តឹងទាក់ទងនឹងមាត្រា 6
ដើម្បីធានាថាមានការដោះស្រាយត្រឹមត្រូវ។

## និយមន័យ

**ដើមបណ្តឹង** (Complainant)៖ បុគ្គលដែលដាក់ពាក្យបណ្តឹងទៅ MassDOT/MBTA។

**ពាក្យបណ្តឹង** (Complaint)៖ ឯកសារស្តីពីការចោទប្រកាន់ទាក់ទងនឹងការរើសអើង
ជាលិខិតសរសេរដោយដៃ ឬ
ជាសារអេឡិចត្រូនិចដែលទាមទារឱ្យការិយាល័យដែលបានទទួលឯកសារនោះចាត់វិធានការដោះ
ស្រាយ។ ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងមានពិការភាព នោះនិយមន័យនៃពាក្យបណ្តឹងនេះ
រាប់បញ្ចូលទាំងទម្រង់ផ្សេងៗដែលជួយសម្រួលដល់ពិការភាពរបស់ដើមបណ្តឹង។

**ការរើសអើង** (Discrimination)៖ សកម្មភាព ឬ អសកម្មភាព ដោយចេតនា ឬ អចេតនា
ចំពោះជនណាម្នាក់ក្នុងសហរដ្ឋអាមេរិកដែលបានទទួលរងភាពមិនស្មើគ្នា ឬ

OLD COLONY PLANNING COUNCIL

Rebecca Coletta, President | Mary Waldron, Executive Director

(508) 583-1833 | 70 School Street, Brockton, MA 02301 | www.oldcolonyplanning.org

ភាពខុសគ្នាដាច់ស្រឡះក្នុងសកម្មភាពឬកម្មវិធីណាមួយដែលទទួលជំនួយពីសហព័ន្ធ ដោយសារតែជាតិសាសន៍, ពណ៌សម្បុរ ដើមកំណើត ឬលក្ខណៈផ្សេងទៀតដែលទទួលស្គាល់ដោយអាជ្ញាធរទប់ស្កាត់ការរើសអើងដូចជា ភេទ អាយុ ឬពិការភាព។

**រដ្ឋបាលប្រត្តិបត្តិការ** (Operating Administrations)៖ ភ្នាក់ងារផ្សេងៗនៃនាយកដ្ឋានដឹកជញ្ជូនរបស់សហរដ្ឋអាមេរិក រួមមាន រដ្ឋបាលផ្លូវធំរបស់សហព័ន្ធ (FHWA: Federal Highway Administration) រដ្ឋបាលសេវាធ្វើដំណើរសាធារណៈរបស់សហព័ន្ធ (FTA: Federal Transit Administration) រដ្ឋបាលផ្លូវដែកសហព័ន្ធ (FRA: Federal Rail Administration) រដ្ឋបាលសុវត្ថិភាពចរាចរណ៍ផ្លូវជាតិ (NHTSA: National Highway Traffic Safety Administration) និងរដ្ឋបាលសុវត្ថិភាពក្រុមហ៊ុនដឹកជញ្ជូនរថយន្តសហព័ន្ធ (FMCSA: Federal Motor Carrier Safety Administration) ដែលផ្តល់ជំនួយសម្រាប់សកម្មភាព ឬកម្មវិធីទាំងឡាយណាទាក់ទងនឹងការដឹកជញ្ជូន។

**ចុងបណ្តឹង** (Respondent)៖ បុគ្គល ភ្នាក់ងារ ស្ថាប័ន ឬ អង្គការដែលត្រូវបានចោទប្រកាន់ថាមានជាប់ពាក់ព័ន្ធនឹងការរើសអើង។

## ការដាក់ពាក្យបណ្តឹង

ផ្នែកនេះនឹងរៀបរាប់លម្អិតអំពីនីតិវិធីរបស់នាយកដ្ឋានដឹកជញ្ជូនរដ្ឋម៉ាសាឈូសេត (MassDOT/MBTA) ក្នុងការចាត់ចែងពាក្យបណ្តឹងស្តីពីការរើសអើងមាត្រា 6 (រើសអើងដោយសារជាតិសាសន៍ ពណ៌សម្បុរ ឬដើមកំណើត រួមបញ្ចូលទាំងភាសា) និងពាក្យបណ្តឹងស្តីពីការរើសអើងដែលមានចែងបន្ថែមក្នុងច្បាប់ស្តីពីភាពគ្មានការរើសអើងរបស់សហព័ន្ធ (រើសអើងដោយសារ ភេទ អាយុ ឬពិការភាព)។ ច្បាប់និងនីតិបញ្ញត្តិរបស់សហព័ន្ធដែលគ្របដណ្តប់មាត្រា 6 នៃច្បាប់ស្តីពីសិទ្ធិពលរដ្ឋឆ្នាំ1964 (មាត្រា 6) ផ្តល់សិទ្ធិអំណាចសម្របសម្រួលក្នុងការស៊ើបអង្កេតពាក្យបណ្តឹងទាក់ទងនឹងសិទ្ធិពលរដ្ឋទៅឱ្យក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក (US DOT) ដែលសហការយ៉ាងជិតស្និទ្ធជាមួយនិងភ្នាក់ងារសហព័ន្ធដែលមានទំនួលខុសត្រូវនេះ។ ក្នុងវិស័យដឹកជញ្ជូន សិទ្ធិអំណាចស៊ើបអង្កេតនេះស្ថិតក្នុងដៃក្រសួងដឹកជញ្ជូនសហរដ្ឋអាមេរិក (US DOT) និងភ្នាក់ងារផ្សេងៗរបស់នាយកដ្ឋាននេះសម្រាប់មធ្យាបាយដឹកជញ្ជូនផ្សេងៗ រួមទាំងរដ្ឋបាលផ្លូវធំរបស់សហព័ន្ធ (FHWA) និងរដ្ឋបាលសេវាធ្វើដំណើរសាធារណៈរបស់សហព័ន្ធ (FTA)។ ដើម្បីឱ្យស្របទៅតាមលក្ខខណ្ឌរបស់ក្រសួងដឹកជញ្ជូនសហរដ្ឋអាមេរិក FHWA និងFTA បានបង្កើតបទបញ្ញត្តិ និងការណែនាំ ដែលតម្រូវឱ្យអ្នកទទួលជំនួយ និងអ្នកទទួលជំនួយសហព័ន្ធបន្ត បង្កើតនីតិវិធីសំរាប់ចាត់ចែងពាក្យបណ្តឹងមាត្រា6 ដែលគេបានដាក់ជាមួយនឹងអង្គភាពទាំងនេះ។

នីតិវិធីដែលមានរៀបរាប់ខាងក្រោម ត្រូវបានកែសម្រួលពីនីតិវិធីដែលត្រូវបានណែនាំឱ្យប្រើប្រាស់

ដោយក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក (US DOJ) ហើយត្រូវបានរៀបចំឡើង ដើម្បីផ្តល់ឱកាសស្មើភាពមួយ ក្នុងការដោះស្រាយពាក្យបណ្តឹងដែលគោរពតាមនីតិវិធីត្រឹមត្រូវ ឱ្យទាំងដើមបណ្តឹង និងចុងបណ្តឹង។
ក្រៅពីនីតិវិធីដោះស្រាយពាក្យបណ្តឹងជាផ្លូវការដែលបានរៀបរាប់ជាលម្អិតនៅទីនេះ MassDOT/MBTA នឹងចាត់វិធានការទប់ស្កាត់ការរើសអើង ដើម្បីស្វែងរកដំណោះស្រាយក្រៅផ្លូវការចំពោះពាក្យបណ្តឹងមាត្រា 6 ទាំងអស់នៅពេលណាដែលអាចធ្វើបាន។

# ដំណើរការនៃការដាក់ពាក្យបណ្តឹង

## 1. តើអ្នកណាអាចដាក់ពាក្យបណ្តឹងបាន?

**គ្រប់**សាធារណជន រួមទាំងអតិថិជន បេក្ខជន ក្រុមហ៊ុនម៉ៅការ ឬ អ្នកទទួលជំនួយបន្តរបស់ MassDOT/MBTA ទាំងអស់ដែលយល់ថា ពួកគេផ្ទាល់ ឬភាគីទីបី ឬក្រុមណាមួយទទួលរងការធ្វើបាប ឬការប្រព្រឹត្តមិនស្មើភាពដោយសារតែជាតិសាសន៍ ពណ៌សម្បុរ ឬដើមកំណើត (រួមទាំង ចំណេះដឹងភាសាអង់គ្លេសមានកម្រិត) ដែលល្មើសនឹងមាត្រា 6 នៃច្បាប់ស្តីពីសិទ្ធិពលរដ្ឋឆ្នាំ1964 ពាក់ព័ន្ធនឹងដីការ និងច្បាប់រដ្ឋ និងសហព័ន្ធ ឬល្មើសនឹងគោលនយោបាយប្រឆាំងការរើសអើង/ទប់ស្កាត់ការបៀតបៀនរបស់ MassDOT/MBTA (ADHP)។ មាត្រា 6 និងគោលការណ៍ ADHP ក៏បានហាមមិនឱ្យមានការសងសឹកចំពោះសាធារណជន ដោយសារតែមូលហេតុជាតិសាសន៍ ពណ៌សម្បុរ ឬដើមកំណើតផងដែរ។

## 2. តើខ្ញុំដាក់ពាក្យបណ្តឹងដោយរបៀបណា?

ពាក្យបណ្តឹងអាចដាក់បានតាមរយៈ ៖

**MassDOT/MBTA Title VI Specialists**
Office of Diversity and Civil Rights – Title VI Unit
10 Park Plaza, Suite 3800
Boston, MA 02116
ទូរស័ព្ទ៖ (857) 368-8580 ឬ 7-1-1 សេវាកម្មសម្រាប់ជនពិការ
អ៊ីម៉េល៖ MassDOT.CivilRights@state.ma.us ឬ MBTAcivilrights@mbta.com

**MassDOT/MBTA, Assistant Secretary and Chief Diversity Officer**
Office of Diversity and Civil Rights – Investigations Unit
10 Park Plaza, Suite 3800
Boston, MA 02116
ទូរស័ព្ទ៖ (857) 368-8580
អ៊ីម៉េល៖ odcrcomplaints@dot.state.ma.us

**មជ្ឈមណ្ឌលទំនាក់ទំនងអតិថិជនសម្រាប់ MBTA**៖ (617) 222-3200
បុគ្គលិកមជ្ឈមណ្ឌលហៅទូរសព្ទ នឹងទទួលបានព័ត៌មានមូលដ្ឋានអំពីបញ្ហានេះពីអ្នកហៅទូរសព្ទ។ ព័ត៌មានលម្អិតនៃការហៅទូរសព្ទនឹងត្រូវបញ្ជូនបន្តទៅ ការិយាល័យសិទ្ធិពលរដ្ឋនិងចម្រុះរបស់ ដើម្បីដំណើរការ។

**U.S. Department of Transportation**
Office of Civil Rights
1200 New Jersey Avenue, SE
Washington, DC 20590
គេហទំព័រ៖ civilrights.justice.gov/

**Old Colony Planning Council**
Title VI/ Nondiscrimination Coordinator
Mary Waldron
70 School Street
Brockton, MA 02301
ទូរស័ព្ទ៖ (508) 583-1833
អ៊ីម៉េល៖ mwaldron@ocpcrpa.org

**សូមកំណត់ចំណាំថា៖**

- នៅពេល FTA ទទួលពាក្យបណ្ដឹងមាត្រា 6 ទាក់ទងនឹង MassDOT/MBTA អ្នកទទួលជំនួយបន្ត ឬក្រុមហ៊ុនម៉ៅការ នោះFTA អាចស្នើ MassDOT/MBTA ឱ្យស៊ើបអង្កេតករណីនេះ។
- ប្រសិនបើពាក្យបណ្ដឹងមាត្រា6 ត្រូវបានដាក់ទៅឱ្យ MassDOT ដោយចោទអង្គភាពផ្នែកផ្លូវធំរបស់ MassDOT (MassDOT's Highway Division)ពីបទបំពាន នោះពាក្យបណ្ដឹងនឹងត្រូវបញ្ជូនបន្តទៅ ការិយាល័យផ្នែក FHWA ប្រចាំតំបន់ដែលនឹងបញ្ជូនពាក្យបណ្ដឹងបន្តទៅការិយាល័យកណ្ដាលផ្នែកសិទ្ធិពលរដ្ឋរបស់ FHWA សម្រាប់ចាត់ការបន្ត។
- ប្រសិនបើ FMCSA ទទួលបានពាក្យបណ្ដឹងប្រឆាំងនឹង MassDOT នោះ FMCSA នឹងបញ្ជូនពាក្យបណ្ដឹងទៅ MassDOT សម្រាប់ការឆ្លើយតបជាលាយលក្ខណ៍អក្សរ។ នេះអនុញ្ញាតឱ្យ MassDOT ដោះស្រាយពាក្យបណ្ដឹង ឬផ្ដល់ការឆ្លើយតបជាលាយលក្ខណ៍អក្សរចំពោះការចោទប្រកាន់។ ការឆ្លើយតបជាលាយលក្ខណ៍អក្សរត្រូវបានប្រើដើម្បីកំណត់ថាតើជំហានណាដែល FMCSA នឹងចាត់វិធានការដើម្បីដំណើរការបណ្ដឹង។

## 3. តើខ្ញុំត្រូវមានអ្វីខ្លះនៅក្នុងពាក្យបណ្ដឹងរបស់ខ្ញុំ?

ទម្រង់បែបបទនៃពាក្យបណ្ដឹងមាត្រា 6/ភាពគ្មានការរើសអើង អាចទាញយកបានតាមរយៈប្រព័ន្ធអេឡិចត្រូនិច ពីគេហទំព័រមាត្រា 6របស់MassDOT

OLD COLONY
PLANNING COUNCIL

Rebecca Coletta, President | Mary Waldron, Executive Director

(508) 583-1833 | 70 School Street, Brockton, MA 02301 | www.oldcolonyplanning.org

គេហទំព័រ មាត្រា 6របស់MBTA ឬ ជាទម្រង់ក្រដាសបំពេញដោយដៃ ពីអ្នកជំនាញមាត្រា 6 របស់ MassDOT/MBTA ដែលបានរៀបរាប់ខាងលើ។ ម្យ៉ាងវិញទៀត ដើមបណ្តឹងក៏អាចដាក់ពាក្យបណ្តឹងដែលមានលក្ខណៈស្រដៀងគ្នាក្នុងទម្រង់ផ្សេងទៀតដែលរួមមាន៖

- ឈ្មោះ ហត្ថលេខា និងព័ត៌មានទំនាក់ទំនងក្នុងពេលបច្ចុប្បន្នរបស់អ្នក (ដូចជាលេខទូរស័ព្ទ និងអាសយដ្ឋាន)
- ឈ្មោះ និងលេខសម្គាល់របស់ជនជាប់ចោទ (ប្រសិនបើអ្នកដឹង ហើយប្រសិនបើចាំបាច់)
- ការរៀបរាប់ពីពេលវេលា ទីកន្លែង និងវិធីដែលទង្វើហាមឃាត់ ដែលអ្នកកំពុងចោទប្តឹងនេះបានកើតឡើង
- ការរៀបរាប់លម្អិតថាតើហេតុអ្វីបានជាអ្នកយល់ថា គេប្រព្រឹត្តិទៅលើអ្នក ខុសពីអ្នកដទៃ
- ឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់សាក្សី និង
- ព័ត៌មាននានាទាំងឡាយណាដែលអ្នកយល់ថាមានជាប់ទាក់ទងនឹងពាក្យបណ្តឹងរបស់អ្នក

ក. ក្នុងករណីដែលដើមបណ្តឹងមិនអាចផ្តល់លិខិតជាលាយលក្ខណ៍អក្សរបានទេ ពាក្យបណ្តឹងជាពាក្យសំដីអាចធ្វើទៅបានទៅកាន់ការិយាល័យសិទ្ធិពលរដ្ឋ និងចម្រុះ (ODCR)។ ដើមបណ្តឹងនឹងត្រូវសម្ភាសដោយមន្ត្រីស៊ើបអង្កេតសិទ្ធិពលរដ្ឋ (CRI)។ ប្រសិនបើចាំបាច់ មន្ត្រី CRI នឹងជួយដើមបណ្តឹងក្នុងការប្រែក្លាយពាក្យបណ្តឹងជាពាក្យសំដី មកជាពាក្យបណ្តឹងលាយលក្ខណ៍អក្សរ។ ដើមបណ្តឹងគួរតែចុះហត្ថលេខាលើគ្រប់ពាក្យបណ្តឹងទាំងអស់។

ខ. ពាក្យបណ្តឹងអនាមិកអាចនឹងដាក់តាមវិធីដូចគ្នា។ ពាក្យបណ្តឹងអនាមិកនឹងត្រូវបានស៊ើបអង្កេតតាមវិធីដូចគ្នានឹងពាក្យបណ្តឹងដទៃទៀត។

គ. ពាក្យបណ្តឹងសរសេរជាភាសាណាក៏ដោយដែលត្រូវបានគេទទួល។ បែបបទពាក្យបណ្តឹងជាដែល សរសេរជាពីភាសាក៏មានផ្តល់ជូនផងដែរ។

## 4. តើខ្ញុំត្រូវដាក់ពាក្យបណ្តឹងក្នុងរយៈពេលប៉ុន្មាន?

ក. ពាក្យបណ្តឹងចោទប្រកាន់ពីបទល្មើសមាត្រា 6 និង/ឬ គោលការណ៍ADHPរបស់MassDOT/MBTA ត្រូវដាក់ មិនឱ្យលើសមួយរយប៉ែតសិបថ្ងៃ (180) ចាប់ពីថ្ងៃដែលបទល្មើសបានកើតឡើង។

ខ. ពាក្យបណ្តឹងចោទប្រកាន់ពីបទល្មើសច្បាប់រដ្ឋ ឬសហព័ន្ធ ត្រូវដាក់ក្នុងអំឡុងពេលដែលកំណត់ដោយបញ្ញត្តិ បទបញ្ជា ឬច្បាប់យុត្តិសាស្ត្រ៖ ក្នុងករណីខ្លះរហូតដល់បីរយ (300) ថ្ងៃគិតចាប់ពីថ្ងៃនៃការរំលោភដែលបានចោទប្រកាន់។

OLD COLONY PLANNING COUNCIL

Rebecca Coletta, President | Mary Waldron, Executive Director

(508) 583-1833 | 70 School Street, Brockton, MA 02301 | www.oldcolonyplanning.org

## 5. តើពាក្យបណ្ដឹងរបស់ខ្ញុំនឹងត្រូវដោះស្រាយដោយរបៀបណា?

នៅពេលដែលពាក្យបណ្ដឹងត្រូវបានទទួល ពាក្យបណ្ដឹងនោះនឹងត្រូវបានប្រគល់ឱ្យទៅមន្ត្រីស៊ើបអង្កេតសិទ្ធិពលរដ្ឋ (CRI)។ មន្ត្រីCRIនេះនឹង៖

ក. កំណត់ដែនសមត្ថកិច្ច៖ ODCR មានដែនសមត្ថកិច្ច ប្រសិនបើពាក្យបណ្ដឹង៖

1. ពាក់ព័ន្ធនឹងការអះអាង ឬ ការប្រព្រឹត្តិដែលរំលោភបំពាន៖

   - ការប្ដេជ្ញាចិត្ត និង កាតព្វកិច្ចផ្លូវច្បាប់របស់ MassDOT/MBTA ដើម្បីទប់ស្កាត់ការរើសអើង ការរំលោភបំពាន ឬ ការសងសឹក ដោយពឹងផ្អែកទៅលើលក្ខណៈការពារ ចំពោះផ្នែកណាមួយនៃសេវាកម្មផ្ដល់ដោយភ្នាក់ងារជូនសាធារណជន។

     ឬ

   - ការប្ដេជ្ញាចិត្តធ្វើឡើងដោយអ្នកទទួលជំនួយបន្ត និងក្រុមហ៊ុនម៉ៅការដែលកំពុងធ្វើការជាមួយ MassDOT/MBTA ប្រកាន់ខ្ជាប់នឹងគោលការណ៍របស់ MassDOT/MBTA ហើយ

   និង

2. ពាក្យបណ្ដឹងនេះត្រូវបានដាក់ទាន់ពេលវេលា។

ខ. ជូនដំណឹងថាបានទទួលពាក្យបណ្ដឹង ហើយផ្ដល់សេចក្ដីសម្រេចដែនសមត្ថកិច្ច ក្នុងរយៈពេល 10 ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យបណ្ដឹងនេះ។

1. ប្រសិនបើមន្ត្រី CRI សម្រេចថា ពាក្យបណ្ដឹងមិនមានពាក់ព័ន្ធនឹងការបំពានសិទ្ធិពលរដ្ឋ នោះមន្ត្រី CRI នឹងផ្ដល់ដំណឹងទៅដើមបណ្ដឹង និងអ្នកជំនាញមាត្រា 6 ជាលាយលក្ខណ៍អក្សរអំពីលទ្ធផល ហើយករណីនោះនឹងត្រូវបញ្ចប់។

គ. ធ្វើការស៊ើបអង្កេតយ៉ាងល្អិតល្អន់លើការចោទប្រកាន់ដែលមាននៅក្នុងពាក្យបណ្ដឹង ស្របទៅតាមនីតិវិធីនៃការដាក់ពាក្យបណ្ដឹងផ្ទៃក្នុងរបស់ MassDOT/MBTA។

OLD COLONY
PLANNING COUNCIL

Rebecca Coletta, President | Mary Waldron, Executive Director

(508) 583-1833 | 70 School Street, Brockton, MA 02301 | www.oldcolonyplanning.org

## 6. លទ្ធផល និងការណែនាំ

នៅពេលបញ្ចប់ការស៊ើបអង្កេត មន្ត្រី CRI នឹងផ្ញើរលិខិតមួយ ក្នុងចំណោមលិខិតទាំងបីខាងក្រោមទៅដើមបណ្តឹង និងចុងបណ្តឹងអាស្រ័យទៅលើលទ្ធផលនៃការស៊ើបអង្កេត៖

ក. លិខិតបញ្ជាក់ពីដំណោះស្រាយដែលពន្យល់ចុងបណ្តឹងពីវិធានការដែលចុងបណ្តឹងបានអនុវត្ត ឬនឹង អនុវត្តដើម្បីអនុវត្តតាមមាត្រា 6។

ខ. លិខិតបញ្ជាក់ពីលទ្ធផលថា ចុងបណ្តឹងបានប្រព្រឹត្តត្រឹមត្រូវទៅតាមមាត្រា 6។ លិខិតនេះនឹងមានការពន្យល់បកស្រាយអំពីមូលហេតុដែលចុងបណ្តឹងត្រូវបានរកឃើញថាបានប្រព្រឹត្តត្រឹមត្រូវ និងផ្តល់ព័ត៌មានទៅដើមបណ្តឹងថាដើមបណ្តឹងមានសិទ្ធប្តឹងជំទាស់។

គ. លិខិតបញ្ជាក់ពីលទ្ធផលថា ចុងបណ្តឹងត្រូវបានរកឃើញថាបានប្រព្រឹត្តខុស។ លិខិតនេះនឹងបញ្ជាក់ពីបទល្មើសនីមួយៗ ដោយយោងទៅតាមបទបញ្ជាដែលកំពុងដាក់ឱ្យប្រើប្រាស់ ការរៀបរាប់សង្ខេបអំពីលទ្ធផល/ការណែនាំ ផលវិបាកនៃការមិនបានបំពេញការប្រព្រឹត្តតាមច្បាប់ដោយស្ម័គ្រចិត្ត និងសំណើរផ្តល់ជំនួយក្នុងការរៀបចំផែនការអនុលោមតាមច្បាប់ ប្រសិនបើសមស្រប។

## 7. តើខ្ញុំអាចប្តឹងជំទាស់លទ្ធផលបានទេ?

ប្រសិនបើដើមបណ្តឹង ឬ ចុងបណ្តឹងមិនយល់ស្របនឹងការរកឃើញរបស់មន្ត្រីCRIទេ គេអាចប្តឹងជំទាស់ទៅជំនួយការលេខាធិការនៃការិយាល័យសិទ្ធិពលរដ្ឋនិងចម្រុះ។ ភាគីប្តឹងជំទាស់ត្រូវតែផ្តល់**ព័ត៍មានថ្មីណាមួយដែលមិនមានក្នុងអំឡុងពេលស៊ើបអង្កេតដំបូង ដែលនឹងធ្វើឱ្យ MassDOT/MBTA ពិចារណាលើការសម្រេចរបស់ខ្លួនសារជាថ្មីម្តងទៀត។** ពាក្យស្នើប្តឹងជំទាស់ និងព័ត៍មានថ្មីទាំងឡាយត្រូវតែដាក់បញ្ជូនមកក្នុងរយៈពេល 30 ថ្ងៃ រាប់ចាប់ពីថ្ងៃដែលលិខិតបញ្ជាក់លទ្ធផលបានបញ្ជូនចេញទៅ។ បន្ទាប់ពីធ្វើការពិនិត្យសើរើព័ត៍មាននេះ MassDOT/MBTA នឹងឆ្លើយតប ដោយចេញលិខិតបញ្ជាក់ដំណោះស្រាយដែលពួកគេបានកែសម្រួល ឬ ផ្តល់ដំណឹងទៅភាគីប្តឹងជំទាស់ថា លិខិតបញ្ជាក់អំពីដំណោះស្រាយ ឬលិខិតបញ្ជាក់អំពីលទ្ធផលច្បាប់ដើមនៅតែមានប្រសិទ្ធភាព។